# ប៉ីពក

ឧបករណ៍តន្ត្រីគ្រឿងផ្លុំដែលមានអណ្តាតនៅប្រទេសកម្ពុជា រួមមាន អណ្តាតមួយ ឬមួយស្រទាប់ (គឺស្នែងនិងប៉ីពក) អណ្តាតពីរឬពីរស្រទាប់ (គឺប៉ីបបុស ប៉ីប្របុស ឬប៉ីអរ) និងអណ្តាតបួនឬបួនស្រទាប់ (គឺស្រឡៃ)។

ឧបករណ៍ ប៉ីពក ជាឧបករណ៍ដែលគេផ្លុំពីជំហៀង ប្លែកពីឧបករណ៍ឯទៀតដែលគេផ្លុំពីមុខៗ តួរបស់វា ជាទូទៅ ធ្វើអំពីឫស្សីមួយប្រភេទមានឈ្មោះថា "ពក" ដែលគេប្រសិទ្ធនាមដល់ឧបករណ៍តន្ត្រីនេះ។ ប៉ីពកមានរន្ធម្រាមដៃ៧ និងរន្ធមេដៃ១។ អណ្តាតប៉ីពកធ្វើពីសំរិទ្ធឬដែកថែប ដោយដាក់បង្កប់នៅក្នុងបំពង់ពកប្រមាណ ២.៥ សង់ទីម៉ែត្រ ពីខាងចុងនៃតួឧបករណ៍។ ចម្ងាយសំឡេងរបស់ប៉ីពក មានប្រមាណប្រាំបីសំឡេង។

ស្រដៀងនឹងឧបករណ៍ "ស្នែង" ដែលជាឧបករណ៍គ្រឿងផ្លុំ មានអណ្តាតមួយឬមួយស្រទាប់ដូចគ្នាដែរ គេប្រើ "ប៉ីពក" នៅក្នុងវង់ភ្លេងអារក្ខ ដើម្បីអន្ទងអញ្ជើញព្រលឹងឲ្យមកសណ្ឋិតនិងមានវត្តមាននៅក្នុងពិធី។ យើងក៏អាចឃើញមានឧបករណ៍ ប៉ីពក ប្រើនៅក្នុងវង់ភ្លេងអាពាហ៍ពិពាហ៍ ដើម្បីអញ្ជើញមេបានិងព្រលឹងបុព្វជនឲ្យមកចូលរួមនៅក្នុងពិធីអាពាហ៍ពិពាហ៍នេះដែរ។[១] នាសម័យដើម យើងក៏មានឃើញគេប្រើឧបករណ៍ ប៉ីពក ជំនួសឧបករណ៍ "ស្នែង" នៅក្នុងពិធីទាក់ដំរី ដើម្បីអញ្ជើញគ្រូមកប្រសិទ្ធពរជ័យដល់ហ្មដំរី មុននឹងចេញទៅទាក់ដំរី។[២] សព្វថ្ងៃ "ប៉ីពក" ត្រូវបានគេលេងជាឧបករណ៍ទោល ឬដើម្បីកំដរអ្នកច្រៀងតែប៉ុណ្ណោះ។

[១] កែវ ណារុំ ២០១១: ៦៤

[២] កែវ ណារុំ ២០១១: ៦៤

អត្ថបទដោយៈ កញ្ញា ម៉ី

# ឯកសារពិគ្រោះ

កែវ ណារុំ. (២០១១). *តន្ត្រីនៅប្រទេសខ្មែរ*. គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។

Sam, Sam-Ang. (2001). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.




ប៉ីពក (ប្រភព៖ Sovichet Tep)

KHMER CIVILIZATION



ប៉ីពក (ប្រភព៖ Sovichet Tep)




អត្ថបទដោយ៖ កញ្ញា ម៉ី



ការផ្លុំប៉ីពក (ប្រភពៈ YouTube)



ការផ្លុំប៉ីពក (ប្រភពៈ YouTube)

អត្ថបទដោយៈ កញ្ញា មុី